**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០៣-សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួលក្នុងការសិក្សាបឋម និងត្រួតពិនិត្យគម្រោងវិនិយោគស្ថាបនាផ្លូវហាយវេថ្មី តភ្ជាប់ពីភ្នំពេញទៅក្រុងព្រះសីហនុ ឆ្លងកាត់ខេត្តតាកែវ និងខេត្តកំពត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

## ស ម្រេ ច

**ប្រការ ១ :** បង្កើតគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួលក្នុងការសិក្សាបឋម និងត្រួតពិនិត្យគម្រោងវិនិយោគស្ថាបនាផ្លូវហាយវេថ្មី តភ្ជាប់ពីភ្នំពេញទៅក្រុងព្រះសីហនុ ឆ្លងកាត់ខេត្តតាកែវ និងខេត្តកំពត ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **ព្រាំ អ៊ីវតឹក** រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធាន

២- ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣- ឯកឧត្តម **វង្សី វិស្សុត** អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

| | | | |
|---|---|---|---|
| ៤- ឯកឧត្តម | **ផា វ៉ាន់ដេត** | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- ឯកឧត្តម | **ស្រី បេន** | អភិបាលខេត្តតាកែវ | សមាជិក |
| ៦- ឯកឧត្តម | **ថាច់ ឃេន** | អភិបាលខេត្តកំពត | សមាជិក |
| ៧- ឯកឧត្តម | **សាយ ហាក់** | អភិបាលក្រុងព្រះសីហនុ | សមាជិក |
| ៨- លោក | **ភី សុភាត់** | អគ្គនាយករងសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩- លោក | **គីម បូរី** | ប្រធាននាយកដ្ឋានផ្លូវថ្នល់ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- លោក | **តឹករ៉េត សំរេច** | ជំនួយការឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

**ប្រការ ២ :** គណៈកម្មការបច្ចេកទេសនេះ មានភារកិច្ចដូចតទៅ :

- សម្របសម្រួលការសិក្សាបឋម ត្រួតពិនិត្យគម្រោងវិនិយោគ ពិនិត្យកិច្ចសន្យាផ្សេងៗនៃគម្រោងស្ថាបនាផ្លូវហាយវេ ភ្នំពេញ-ក្រុងព្រះសីហនុ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធចាំបាច់តាមបណ្តោយផ្លូវថ្មីនេះ ។
- សម្របសម្រួលក្នុងការដោះស្រាយគោលនយោបាយដីធ្លីសមស្រប លើដីដែលប៉ះពាល់ពីគម្រោងវិនិយោគនេះ ។
- ត្រួតពិនិត្យការអនុវត្តគម្រោង ការសាងសង់ និងការងារផ្សេងៗ ដែលពាក់ព័ន្ធនឹងគម្រោងនេះ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ [illegible] ១៩ ឆ្នាំ ២០០៧*

**ហ៊ុន សែន**

*កន្លែងទទួល:*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ-កាលប្បវត្តិ*